ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និង ដឹកជញ្ជូន
លេខ : 123 ប្រក.សក.បជ

ភ្នំពេញ, ថ្ងៃទី 21 ខែ 03 ឆ្នាំ ២០០៣

# ប្រកាស

## ស្ដីពីការដាក់អោយសាលាបច្ចេកទេស ហ៊្សី វ៉ េ សេ
## ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួងសាធារណការ និង ដឹកជញ្ជូន

## រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០.១១.១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងសាធារណការ និង ដឹកជញ្ជូន ។
- បានឃើញ អនុក្រឹត្យលេខ ១៤/អនក្រ.បក ចុះថ្ងៃទី ០៣.០៣.១៩៩៨ ស្ដីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ។
- យោងលិខិតលេខ ១៩៨៤.សជណ ចុះថ្ងៃទី ២២.១២.២០០០ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ស្ដីពីសំណើសុំលក់អចលនទ្រព្យរបស់ក្រុមហ៊ុនដឹកជញ្ជូនដោយរថយន្ត ចំនួនប្រាំកន្លែង ដែលមានក្រុមហ៊ុន សូគីមិច ជាអ្នកទិញ ។
- យោងលិខិតលេខ ០០៣/មស.ក្រខ ចុះថ្ងៃទី ០៨.០១.២០០៣ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ស្ដីពីសំណើសុំបញ្ចូលក្របខ័ណ្ឌមន្ត្រី-រាជការ ចំនួន ៣១ រូប ពីក្រុមហ៊ុនដឹកជញ្ជូន ដោយរថយន្ត មកក្នុងក្របខ័ណ្ឌបុព្វហេតុរដ្ឋបាល នៃ ក្រសួងសាធារណការ និង ដឹកជញ្ជូន ។
- យោងកិច្ចព្រមព្រៀងរវាងក្រសួងសាធារណការ និង ដឹកជញ្ជូន នៃព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងអង្គការស្ម័គ្រចិត្តអន្តរជាតិនៃប្រទេសជប៉ុន J V C ។
- យោងតាមការចាំបាច់របស់ក្រសួងសាធារណការ និង ដឹកជញ្ជូន ។

## សម្រេច

**ប្រការ ១ :** ត្រូវបានផ្ទេរការងារគ្រប់គ្រងសាលាបច្ចេកទេស ហ៊្សី វ៉េ សេ នៃ ក្រុមហ៊ុនដឹកជញ្ជូនដោយរថយន្ត អោយមកស្ថិតនៅក្រោមការគ្រប់គ្រង នឹងដឹកនាំផ្ទាល់របស់ក្រសួងសាធារណការ និង ដឹកជញ្ជូន ។

**ប្រការ ២ :** ការរៀបចំ និង ការប្រព្រឹត្តទៅរបស់សាលាបច្ចេកទេស ហ៊្សី វ៉េ សេ នឹងត្រូវកំណត់ដោយបទដ្ឋានដោយឡែក ។

**ប្រការ ៣ :** នាយកខុទ្ទកាល័យ, អគ្គនាយក នៃ អគ្គនាយកដ្ឋានរដ្ឋបាល, អគ្គនាយក នៃ អគ្គនាយកដ្ឋានសាធារណការ អគ្គនាយក នៃ អគ្គនាយកដ្ឋានដឹកជញ្ជូន និង អគ្គាធិការ នៃ អគ្គាធិការដ្ឋាន ត្រូវទទួលបន្ទុកអនុវត្តរៀងៗខ្លួនតាមខ្លឹមសារ នៃ ប្រកាសនេះដែលចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**កន្លែងទទួល :**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច-ហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

**ដើម្បីជូនជ្រាបជាពត៌មាន**

- ដូចប្រការ ៣

**ដើម្បីអនុវត្ត**

- ឯកសារ-កាលប្បវត្តិ

រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

ខឹម តាំងលីម